# សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក
## ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦

អ.វ.ត.ក មានក្តីសោមនស្សរីករាយសូមជម្រាបថា មន្ត្រីតុលាការជាតិ និងអន្តរជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងធ្វើសម្បថចូលកាន់មុខតំណែងនៅក្នុងពិធីមួយ នាវេលាម៉ោង ៤ រសៀល ថ្ងៃច័ន្ទ ទី៣ ខែកក្កដា នៅចំពោះមុខរូបសំណាកអតីតព្រះមហាក្សត្រ ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) ក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងតំណាងរបស់អគ្គលេខាធិការអង្គការសហប្រជាតិ។

ពិធីធ្វើសម្បថចូលកាន់មុខតំណែងនេះ នឹងបង្កើតជាចំណុចកំពូលនៅក្នុងសប្តាហ៍នេះ ទៅលើសកម្មភាពនានាពាក់ព័ន្ធនឹងមន្ត្រីតុលាការ បុគ្គលិកជាន់ខ្ពស់នៃការិយាល័យរដ្ឋបាល និងធនធានបុគ្គលិកដែលមានជំនាញផ្នែកច្បាប់ជាតិ និងអន្តរជាតិ។

នៅពេលល្ងាច បន្ទាប់ពីពិធីធ្វើសម្បថនេះចប់ទៅ នឹងមានបដិសណ្ឋារកិច្ចមួយនៅសណ្ឋាគាររ៉ូយ៉ាល់ក្រោមអធិបតីភាពរបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម។

នៅថ្ងៃច័ន្ទ ទី៣ ខែកក្កដា មន្ត្រីតុលាការនឹងត្រូវជម្រាបជូនសង្ខេបអំពីរចនាសម្ព័ន្ធ និងការគាំទ្រការងារពីសំណាក់ការិយាល័យរដ្ឋបាលចំពោះអង្គជំនុំជម្រះនានា ហើយនឹងមានដំណើរទស្សនកិច្ចនៅក្នុងបរិវេណតុលាការនេះ។ ចាប់ពីថ្ងៃអង្គារ ទី៤ ខែកក្កដា ដល់ថ្ងៃសុក្រ ទី៧ ខែកក្កដា ពួកគាត់នឹងចូលរួមនៅក្នុងការធ្វើផែនការយុទ្ធសាស្ត្រលម្អិតរបស់តុលាការ និងសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍ ក្នុងគោលបំណងឲ្យមានភាពស៊ាំ ការកសាងក្រុម ការកសាងប្រព័ន្ធ និងការធ្វើសេចក្តីសម្រេច។ ពួកគាត់ក៏នឹងមានឱកាសជួបជាមួយ

តំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកិច្ចការរបស់ អ.វ.ត.ក ពិសេស បណ្ដាអង្គការដែលផ្ដល់កម្មវិធីគាំទ្រ។

*តំណាងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសន្និសីទសារព័ត៌មាន និងក្នុងពិធីថតរូបនៅសណ្ឋាគារលើរ៉ូយ៉ាល់ វេលាម៉ោង ៣.០០ រសៀល នាថ្ងៃសុក្រ ទី៧ ខែកក្កដា។*

*ដោយសារតែកន្លែងមានកំណត់ និងដោយការពិចារណាលើបញ្ហាសន្តិសុខ លទ្ធភាពចូលរួមនៅក្នុងពិធីស្បថចូលកាន់មុខតំណែងនឹងត្រូវបានកម្រិត។ អាស្រ័យហេតុនេះ យើងខ្ញុំសុំស្នើឲ្យតំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានចំណាប់អារម្មណ៍ចូលរួម មេត្តាទាក់ទងមកកាន់លោក រាជ សម្បត្តិ មន្ត្រីផ្នែកព័ត៌មានរបស់ អ.វ.ត.ក តាមរយៈទូរសព្ទលេខ: ០១២ ៨៩១ ៥៦៧ ឬតាមរយៈអ៊ីមែល:* **reachsambath@hotmail.com** *ត្រឹមរសៀលថ្ងៃអាទិត្យ ទី១ ខែកក្កដា នេះ។*

-ចប់-